# អង្គរវត្តជាប្រាសាទឬជាផ្នូរ?*

George Coedès

នៅក្នុងអត្ថបទឈ្មោះថា “Pradakṣiṇa et Prasavya en Indochine”[១] លោក Przyluski លើកឡើងម្តងទៀតនូវទ្រឹស្តីមួយដែលគាត់ធ្លាប់លាតត្រដាងនៅឆ្នាំ ១៩២១ ក្នុងមេរៀនរបស់គាត់នៅ Collège de France ក្នុងគោលបំណងបញ្ជាក់ថា “ដើមឡើយ អង្គរវត្តពុំមែនជាប្រាសាទទេ តែជាផ្នូរ”។

ទ្រឹស្តីនេះផ្អែកលើការសង្កេតពីរជាពិសេស។ ការសង្កេតទីមួយនោះ ខ្ញុំក៏ធ្លាប់លើកឡើងយូរមកហើយដែរ[២] គឺថា នៅអង្គរវត្ត ក្រៅពីចម្លាក់រឿងដែលគេបង្ហាញតួអង្គ ឬចំណុចសំខាន់នៅចំកណ្តាលផ្ទាំង ហើយដែលអ្វីផ្សេងៗទៀតនៅសងខាងជុំវិញនោះ យើងត្រូវដើរមើលរូបពីឆ្វេងទៅស្តាំ កាលណាយើងដើរបែរមុខទៅផ្ទាំងចម្លាក់នោះ។ ឯការសង្កេតទី២ លោកបណ្ឌិត F.D.K. Bosch[៣] ក៏ធ្លាប់លើកឡើងដោយឡែក តែស្របពេលជាមួយគ្នាដែរ គឺថាឈុតរឿងផ្សេងៗទាំងប៉ុន្មាន ហាក់ដូចជាគេរៀបចំបង្ហាញឡើងតាមលំដាប់លំដោយអ្វីមួយដែរ។ អ្នកទាំងពីរយល់ថា គេត្រូវដើរមើលផ្ទាំងចម្លាក់ជុំវិញតាមឧត្តរពាត់[៤]។ ចំពោះលោកបណ្ឌិត Bosch ចម្លាក់នោះផ្តើមឡើងពីរបៀងខាងកើត ចំហៀងខាងត្បូង (រឿងកួរសមុទ្រទឹកដោះ) រីឯលោក Przyluski វិញយល់ថាត្រូវផ្តើមមើលពីរបៀងខាងត្បូង ចំហៀងខាងកើត (រឿងនរកនិងសួគ៌)។

---

* ប្រែសម្រួលដោយ អាំង ជូលាន ពីអត្ថបទដើមឈ្មោះ Aṅkor Vat, temple ou tombeau ? ចុះនៅក្នុង Bulletin de l’École Française d’Extrême-Orient, XXXIII, fasc.1, p. 303 – 309 ។

[១] *Festschrift fűr M. Winternitz zum 70ten Geburtslag*, Leipzig, 1933, pp. 326-332.

[២] *Les bas-reliefs d’Angkor Vat*, BCAI., 1911, p. 173.

[៣] *Notes archéolgiques. IV. Le temple d’Aṅkor Vat*, BEFEO., XXXII, pp. 12-17.

[៤] កំណត់អ្នកប្រែ ៖ ឧត្តរពាត់ជាទិសដើរច្វៃលជុំវិញដែលផ្ទុយពីប្រទក្សិណ គឺពេលដើរត្រូវឱ្យទីដែលដើរពាត់នោះនៅឆ្វេងដៃយើង ឬពោលម្យ៉ាងទៀតថា ផ្ទុយពីទ្រនិចនាឡិកា។ គេច្រើនដើរឧត្តរពាត់ ឬបង្វិលពពិលតាមឧត្តរពាត់នៅពេលបូជាសព។

ខ្ញុំតែងជឿជាក់ថា អង្គរវត្តមាននាទីទាក់ទងនឹងសេចក្ដីស្លាប់ ប៉ុន្តែពុំមែនលោក Przyluski ធ្វើឲ្យអ្នកអានអត្ថបទគាត់យល់ថា ខ្ញុំគិតផ្ទុយអំពីនោះ។ ពិតហើយថា ខ្ញុំបានសរសេរថា “ដើមឡើយ គេសាងអង្គរវត្តដើម្បីឧទ្ទិសទៅព្រះនារាយណ៍” ប៉ុន្តែខ្ញុំមាននិយាយបន្ថែមភ្លាមថា “ការគោរពបូជាទេពនោះ គួរឲ្យសង្ស័យខ្លាំងណាស់ថា ប្រហែលភ្ជាប់ទៅព្រះបាទបរមវិស្ណុលោក ពោលគឺវិញ្ញាណក្ខន្ធនៃមហាក្សត្រដែលគេភ្ជាប់ទៅនឹង ទេពក្រោយពីព្រះអង្គចូលទិវង្គតទៅ”។ ខ្ញុំសរសេរនោះ នៅឆ្នាំ១៩១១ ហើយកាលនោះ យើងមានទិន្នន័យផ្សេងៗស្ទួចស្ទើងនៅឡើយ[៥]។ ឃ្លាទី២នៃអត្ថបទសរសេរតាំងពីឆ្នាំ១៩១១ នោះ[៦] លោក Przyluski កាត់ចោលមិនបានបង្ហាញគេទេ ធ្វើឲ្យអ្នកអានយល់ថា គាត់ជាជនទីមួយដែលដឹងថាអង្គរវត្តមានន័យទាក់ទងនឹងសេចក្ដីស្លាប់។ មិនតែប៉ុណ្ណោះ ដើម្បីឲ្យជឿថាយោបល់គាត់ផ្ទុយពីយោបល់ខ្ញុំ ហើយកាន់តែនាំមុខទៅនោះ គាត់ស្រង់យកឃ្លាមួយចេញពីសេចក្ដីផ្ដើមនៃសៀវភៅ Temple d’Angkor Vat[៧], *ភាគទី៣*, ដែលមាននិយាយថា “ករណីលើកលែងមិនធ្វើតាមក្បួនប្រទក្សិណនោះ មិនខុសអ្វីពីទិសប្លែកពីធម្មតាដែលប្រាសាទបែទៅរកនោះទេ គឺប្រហែលមកពីអង្គរវត្តទាក់ទងនឹងសេចក្ដីស្លាប់”។ ប៉ុន្តែសូមជ្រាបថា សេចក្ដីផ្ដើមដែលគាត់បញ្ជាក់ថាសរសេរដោយ លោក L. Finot នោះ គឺមានចុះឈ្មោះអ្នកនិពន្ធជាអក្សរធំ ថា៖ G. COEDÈS។

យ៉ាងណាក៏យើងស្របគ្នាលើន័យនៃសេចក្ដីស្លាប់នេះដែរ តែត្រូវបញ្ជាក់តទៅទៀតថា អង្គរវត្តជាប្រាសាទនៃព្រះបរមវិស្ណុលោក ឬជាផ្នូរនៃព្រះបាទសូរ្យវរ្ម័នទី២។ ចំពោះលោក Przyluski “មុននឹងជ្រើសរើសយកពាក្យថាប្រាសាទ[៨] ឬផ្នូរ[៩] យើងត្រូវគិតថាកិច្ចពិធីដែលគេធ្វើជំនាន់នោះ សំដៅទៅសពនៃមនុស្ស ឬទៅធាតុអ្វីមួយនៃទេព។ ក្នុងករណីទី១ គឺគេយកឧត្តរពាត់។ បើទី២វិញ គឺប្រទក្សិណ។ យើងឃើញហើយថាផ្ទាំងចម្លាក់នៅអង្គរវត្ត គេរៀបចំឡើងឲ្យដើរមើលជាឧត្តរពាត់ ដូច្នេះជាការខុសទេដែលគេយកពាក្យប្រាសាទមកប្រើ។ ប៉ុន្តែបើតែមនុស្សទូទៅធ្លាប់ហៅថាប្រាសាទអង្គរវត្តតាមអ្នកប្រាជ្ញក្ដី ពាក្យហៅនោះមិនត្រូវតាមមុខងារដើមនៃវិមាននោះឡើយ”។

ហេតុនេះគឺទិសដែលទស្សនិកជនត្រូវដើរមើលផ្ទាំងចម្លាក់នោះឯង ដែលធ្វើឲ្យ លោក Przyluski មើលឃើញអង្គរវត្តថា ពុំមែនជាប្រាសាទសម្រាប់ធ្វើកិច្ចបូជាទេ ឬព្រះមហាក្សត្រណាមួយដែលចូលទិវង្គតឡើយ តែជាផ្នូរដែលគេបញ្ចុះសព ឬធាតុនៃព្រះរាជានោះ សម្រាប់ធ្វើកិច្ចបុណ្យសពតែមួយមុខប៉ុណ្ណោះ។

ទ្រឹស្ដីនេះធ្វើឲ្យលោក Przyluski ពើបប្រទះនឹងបញ្ហាមួយ។ ផ្ទាំងចម្លាក់នៅរបៀងខាងលិចដែលមានទ្វារចូលទៅចំកណ្ដាលនោះ កំណាត់ខាងជើងបង្ហាញឈុតរឿងចម្បាំងនៅកោះលង្កា ឯខាងត្បូងគឺឈុតចម្បាំងនៅ

[៥] *Loc. cit.*, p. 220.

[៦] នៅក្នុងសំណេរឈ្មោះ *Siamese State ceremonies* *ទ.៧០* លោក H. G. Quaritch Wales និយាយថា “លោក Coedès បានបង្ហាញថាគឺជាវាំងស្ដេចពិតហើយ តែស្ដេចដែលចូលទិវង្គតទៅហើយ...”។

[៧] Mémoires archéologiques EFEO., t. II.

[៨] កំណត់អ្នកប្រែ៖ ត្រង់នេះពាក្យបារាំងថា temple។

[៩] កំណត់អ្នកប្រែ៖ ពាក្យបារាំងថា tombeau។

កុរុក្សេត្រ។ ទាំងពីរនេះ គ្មានណាមួយជាផ្នែកដើមនៃចម្លាក់ដែលត្រូវដើរមើលមួយជុំប្រាសាទទេ មិនថាចំពោះគាត់ឬចំពោះលោកបណ្ឌិត Bosch ឡើយ។ លោក.Przyluski យល់ថា "ផ្ទាំងដែលផ្ដើមនាំអ្នកមើលឲ្យទស្សនាលំនៅនៃព្រះមហាក្សត្រដែលសោយទីវង្គត" ទៅនោះ គឺផ្ទាំងនិយាយពីស្ថានសួគ៌និងស្ថាននរក ដែលវាតទីលើជញ្ជាំង កំណាត់ខាងកើតនៃរបៀងខាងត្បូង។ គាត់យល់ថា "ប្រហែលត្រូវចាប់ផ្ដើមមើលពីចំណុចខាងស្ដាំ បន្ទាប់ពីទ្វារខាងត្បូងភ្លាមទៅ"។ ដែលនិយាយនោះ គឺសំដៅទៅជនទូទៅដែលមកទស្សនាក្នុងន័យគោរពបូជា ត្បិតលោក Przyluski ទទួលស្គាល់ដែរថា "ទ្វារកិត្តិយស" នៅខាងលិចហើយដែលជាទ្វារចូលត្រង់ទៅថែវខ្វែងគ្នាយ៉ាងចាប់ភ្នែក[10] នោះច្បាស់ជាមានមុខងារអ្វីមួយហើយ។ គាត់សរសេរថាថែវខ្វែងនេះ "ប្រហែលជាទុកសម្រាប់ឲ្យក្បួនដង្ហែព្រះរាជាចូលទៅ"។ បើគិតតាមគាត់ មានន័យថាច្រកសម្រាប់ចូលទៅមើលពិនិត្យពិច័យផ្ទាំងចម្លាក់ឲ្យបានត្រឹមត្រូវនោះ សាងឡើងសម្រាប់មនុស្សម្នាសាមញ្ញទូទៅ រីឯព្រះរាជាវិញ គេពុំយកចិត្តទុកដាក់ចំពោះព្រះអង្គដល់នោះឡើយ ព្រោះព្រះអង្គត្រូវចាប់ផ្ដើមទតអំពីផ្ទាំងមួយមុនដល់ផ្ទាំងបញ្ចប់ជាមុនសិន ពោលគឺផ្ទាំងនិយាយពីចម្បាំងនៅកុរុក្សេត្រ។

ខ្ញុំបានខំរិះរកចម្លើយគ្រប់ច្រកល្ហក ដើម្បីទម្លុះអាថ៌កំបាំងនេះ គឺរកមើលនៅក្នុងពិធីបូជាសពក្សត្រនៅប្រទេសកម្ពុជានិងប្រទេសសៀមសព្វថ្ងៃដែលច្រើនតែរក្សាប្រពៃណីចាស់ដូចគ្នា ថាតើមានទំនៀមណាមួយដែលអាចឱ្យគិតថាច្រកចូលខាងត្បូងជាច្រកសំខាន់ ឬមានទំនៀមណាថាព្រះមហាក្សត្រពុំយាងដើរមួយជុំទេ តែយាងត្រង់ទៅទ្វារចូលខាងលិចតែម្ដង រីឯប្រជាជនធម្មតាវិញចូលទៅតាមទ្វារខាងត្បូង ក្រោយពីដើរជុំធ្វើឧត្តរពាត់សិន។ ខ្ញុំរកទៅពុំឃើញមានទំនៀមអ្វីបែបនេះទាល់តែសោះ។ នៅបាងកកក៏ដូចជានៅភ្នំពេញ ក្នុងពិធីបូជាសពធំៗនៃព្រះញាតិវង្ស ព្រះរាជាតែងតែយាងដើរធ្វើឧត្តរពាត់។ នៅភ្នំពេញមេរុបែមុខទៅកើត, ព្រះរាជរោងនៅខាងត្បូង, ហើយគេដង្ហែកោដ្ឋមាសចូលក្នុងរាជវតិតាមទ្វារខាងកើត។ គេរំកិលយោងកោដ្ឋនោះឡើងលើកន្លែងដុតមកពីខាងកើតដូចគ្នា។ ព្រះរាជាយាងឡើងគោរពសពតាមជណ្ដើរខាងកើត, ក្សត្រប្រុសៗយាងឡើងតាមជណ្ដើរខាងត្បូង, ជនសាមញ្ញតាមជណ្ដើរខាងជើង។ រីឯស្រីៗឡើងតាមជណ្ដើរខាងលិច[11]។

នៅបាងកក មេរុបែមុខទៅខាងលិច, ព្រះរាជរោងនៅខាងលិច, កោដ្ឋមាសគេដង្ហែចូលរាជវតិតាមទ្វារខាងជើង ហើយគេរំកិលយោងឡើងលើទីបូជាតាមច្រកខាងកើត, ព្រះរាជាយាងឡើងគោរពសពតាមជណ្ដើរខាងលិច, ក្សត្រប្រុសៗនិងសព្វមុខមន្ត្រី ឡើងតាមជណ្ដើរខាងជើង, ស្រីៗឡើងតាមជណ្ដើរខាងត្បូង[12]។ ទំនៀមទាំងពីរនេះ ដូចគ្នាតែនៅត្រង់ថាគេរំកិលកោដ្ឋចូលមកទីបូជាពីខាងកើត។ ទ្វារខាងត្បូងនៃរាជវតិគ្មានតួនាទីអ្វីទាំងអស់៖ នៅភ្នំពេញ ឧត្តរពាត់ពជុំនោះចេញដំណើរពីខាងកើត ឯនៅបាងកកវិញគឺចេញពីខាងជើង។ ដូច្នេះឃើញថាបញ្ហាដែលកើតឡើងពីទ្រឹស្ដីរបស់

---

[10] កំណាត់អ្នកប្រែ៖ ផ្នែកត្រង់នេះនៃអង្គរវត្តហៅថា "ព្រះពាន់"។

[11] A. Leclère, *La crémation et les rites funéraires au Cambodge*, pp. 141, 145. Cf. *BEFEO.*, XXVIII, pp. 632 et suiv.

[12] H. G. Q. Wales, *loc. cit.*, pp. 151-153.

លោក Przyluski នោះគ្មានប្រកដោះស្រាយចេញបានសោះ។

ពុំតែប៉ុណ្ណោះ នៅមានបញ្ហាមួយទៀត។ ប្រសិនបើ "ផ្ទាំងចម្លាក់តគ្នាពីមួយទៅមួយ តាមលំដាប់មួយដែលគ្មានបុរាណវិទូណាម្នាក់មុននេះយល់" ពិតដូចគាត់អះអាងមែន តើហេតុអ្វីបានជាប្រាសាទជ្រុងពាយព្យ ដែលអ្នកទស្សនាតាមឧត្តរពាត់ត្រូវតែឆ្លងកាត់ មុននឹងទៅដល់ឈុតចម្បាំងរាមកេរ្តិ៍នោះ មានចម្លាក់ទាក់ទងនឹងឈុតក្រោយចម្បាំងនោះវិញ (នាងសីតាដើរលុយភ្លើង, ក្បួនត្រទាំងអស់ត្រឡប់ចូលនគរស្រីអយុធ្យា)? ហេតុអ្វីបានជាប្រាសាទជ្រុងនិរតីដែលអ្នកទស្សនាដដែលនោះទៅដល់ ក្រោយពីបានឃើញចម្បាំងនៅកោះលង្កា (និងចម្បាំងនៅកុរុក្សេត្រ) សិននោះ មានចម្លាក់ឈុតរាមកេរ្តិ៍ដែលកើតឡើងមុនចម្បាំងនោះទៅវិញ (ព្រះរាមសម្លាប់មហារីក, ក្រុងពាលីស្លាប់)?

បញ្ហានេះពុំពិសេសអ្វីតែនៅអង្គរវត្តទេ ដរាបណាយើងជឿថា គេឆ្លាក់បង្ហាញតាមលំដាប់លំដោយមួយជាក់ច្បាស់ឥតប្រែប្រួល។ បើទៅពិនិត្យចម្លាក់ប្រាសាទដ៏ទៃទៀតដូចជាប្រាសាទបាភួនដែលសាងមុនអង្គរវត្ត ឬប្រាសាទបាយ័ន្តនិងបន្ទាយឆ្មារដែលសាងក្រោយក៏បញ្ហាដដែលនៅតែចោទឡើង។

នៅបាភួន ចម្លាក់តូចៗដែលនៅលំអទ្វារទាំងបួននៃរោងទងខាងក្នុងក៏បង្ហាញពីឈុតដែលមានប្រភពរឿងដូចអង្គរវត្តដែរ។ ឧទាហរណ៍ បើយើងរកមើលឈុតផ្សេងៗនៃរឿងរាមកេរ្តិ៍ យើងឃើញមាននៅយ៉ទាំងបួន ដោយនៅជិតនោះខាងកើតមានឈុតរឿងមហាភារតនិងខាងត្បូងមានឈុតរឿងព្រះក្រឹស្ណា។ លំដាប់ចម្លាក់ទាំងនោះពុំត្រូវតាមប្រទក្សិណឬតាមឧត្តរពាត់ឡើយ។ ផ្ទាំងទាំងនោះហាក់ដូចជារៀបចំឡើងគ្រាន់តែដើម្បីលំអប្រាសាទប៉ុណ្ណោះ គ្មានយោងតាមលំដាប់ដើរប្រទាក់ជុំវិញសោះ។

នៅបាយ័ន្តយើងឃើញមានចម្លាក់រៀបចំឡើង លើផ្ទាំងជញ្ជាំងធំៗ ដូចនៅអង្គរវត្តដែរ។ ចម្លាក់ខ្លះមើលទៅឃើញថាគេរៀបចំឲ្យនៅជុំវិញតួអង្គ ឬអ្វីមួយសំខាន់ ដែលគេឆ្លាប់ឆ្លាក់នៅចំកណ្ដាលផ្ទាំង។ ចម្លាក់ខ្លះទៀតជាការដង្ហែក្បួនបន្តបន្ទាប់គ្នា។ ទោះបីរូបផ្ទាំងភាគច្រើន យើងពុំទាន់យល់ថានិយាយពីអ្វីច្បាស់ក្ដី ក៏គង់យើងយល់ថាត្រូវមើលតាមបណ្ដោយក្បួនដង្ហែនោះដែរ។ ប៉ុន្តែជួនកាល ក្បួនហែទៅតាមទិសម្ខាង ជួនកាលទៅទិសម្ខាងទៀត។ ឧទាហរណ៍នៅរបៀងក្រៅ, លើជញ្ជាំងខាងលិច, ចំហៀងខាងត្បូង ព្រមទាំងលើជញ្ជាំងខាងត្បូង, ចំហៀងខាងលិច ក្បួននោះហែពីឆ្វេងទៅស្ដាំ។ បើនៅជញ្ជាំងខាងលិច, ចំហៀងខាងជើង និងនៅជញ្ជាំងខាងជើង, ចំហៀងខាងកើតវិញ គឺហែពីស្ដាំទៅឆ្វេង។ បើនៅជញ្ជាំងខាងកើត, ចំហៀងខាងត្បូងផង យើងឃើញមានក្បួនហែពីរ ដែលហាក់ដូចជាចេញដំណើរពីច្រកទ្វារកណ្ដាលដូចគ្នា តែហែចេញទៅទិសបញ្ច្រាសគ្នា។ ទោះជាដើរពាត់មើលរបៀងខាងក្រៅតាមទិសណាឬទិសណា ក៏យើងពុំអាចនិយាយថាទាល់តែដូច្នេះទើបត្រូវ ឬដូច្នោះទើបត្រូវឡើយ។ ឯរបៀងខាងក្នុងក៏ពុំខុសអ្វីពីនេះ ហើយពុំតែប៉ុណ្ណោះ កាន់តែសាំញ៉ាំដោយសារមានជញ្ជាំងទទឹងច្រើនឃាំងរបៀងជាកំណាត់ៗ។ ជញ្ជាំងរបៀងនិមួយៗ បើខិតទៅរកប្រាសាទជ្រុង ឃើញថាមានចម្លាក់លើផ្ទាំងធំៗ ធ្វើឱ្យងាយដើរមើលតាម ប៉ុន្តែបន្ទប់តូចៗ ដែលនៅសងខាងច្រកចូលកណ្ដាល ហើយដែលមានចម្លាក់លើជញ្ជាំងដែរនោះ ពុំអាចទាក់ទងគ្នាពីមួយទៅមួយឡើយ។ ក្នុងករណីនេះ តើយើងអាច

គិតថា គេដើរពាត់ជុំវិញរបៀងនោះ នៅលើថ្លាក្រោមបានឬទេ? ឃើញថាពុំសមសោះ ត្បិតបើនៅថ្លាក្រោម យើងពុំអាចមើលឃើញចម្លាក់ច្បាស់ទេ ហើយម្យ៉ាងទៀតយើងដឹងថា កាលដើមឡើយលើថ្លានេះមានប៉មចំនួនដល់ទៅ១៦ឯណោះ[១៣] ដែលគេសាងឡើងដើម្បីភ្ជាប់របៀងក្នុងទៅរបៀងក្រៅ ដូច្នេះពុំអាចដើរពាត់ជុំវិញតាមនេះបានឡើយ។

បញ្ហាដែលចោទឡើង កាលណាយើងចង់ពន្យល់ផ្ទាំងចម្លាក់តាមការដើរប្រទក្សិណឬឧត្តរពាត់នោះ ប្រហែលកើតមកពីការប្រឡំដ៏ធ្ងន់ធ្ងរមួយទៅវិញទេ។ យើងច្រើនតែគិតហាក់ដូចជាថា សំណង់របស់ព្រះរាជានៅកម្ពុជាសម័យបុរាណធ្វើឡើងក្នុងបំណងឬគំនិតដូចបូជនីយដ្ឋានរបស់យើង[១៤] ឬមួយដូចវត្តលោកសម័យថ្មីនេះដូច្នោះ។ តាមពិតទៅគឺគ្មានអ្វីរបៀបនោះសោះ។ កាលណាយើងសិក្សាផ្ទាំងចម្លាក់ យើងជឿជាស្វ័យប្រវត្តិថា គេឆ្លាក់មកដើម្បីពន្យល់អ្នកទស្សនាហាក់ដូចជាច្បាស់ថា អាចមានអ្នកទស្សនាមានសិទ្ធិអំណាចមកមើលតាមចិត្តដូច្នោះមែន មិនថាអ្នកនោះជាអ្នកមកសំពះគោរពឬធ្វើអ្វីផ្សេងឡើយ។ ខ្ញុំយល់ថាគិតរបៀបនេះខុសទាំងស្រុង។ បើគេធ្វើមកសម្រាប់ឱ្យមនុស្សម្នាទស្សនាមែន គួរណាស់តែរៀបចំផ្លូវដើរឱ្យស្រួល គោរពបូជាបន្តិចទៅ ។ នៅអង្គរវត្តនិងបាយ័ន្ត រោងទងទាំងឡាយសុទ្ធតែជាប់គ្នានៅត្រង់មុខ និងនៅច្រកចូលកណ្ដាល តាមទិសនីមួយៗ។ ជាប់គ្នានេះ គឺជាប់ដោយមានបន្ទប់និងមាត់យ៉បន្ទប់មកឃាំង ហើយកន្លែងជាប់ពីមួយទៅមួយនោះ គឺត្រូវកន្លងកាំមាត់ច្រកយ៉ាងខ្ពស់ដោយប្រឹងប្រែង សមតែហាត់ប្រាណទៅវិញ។ តើធ្វើនេះសម្រាប់ដើរពាត់មែន[១៥]ឬ? បើគិតថាជា ចិត្រសាលា វិញ[១៦]ដូចជាសមជាង។

ប្រាសាទសម្រាប់តម្កល់លិង្គដូចជាបាភួន, វិមានសក្ការៈដែលទាក់ទងនិងកិច្ចសពដូចជាអង្គរវត្ត, វិមានជាទីប្រជុំទេពដូចជាបាយ័ន្ត[១៧] ទាំងនេះសុទ្ធសឹងជាលំនៅស្ថាននៃទេព ដែលគេពុំអាចបកស្រាយពន្យល់តាមទស្សនៈឬបរិបទពីខាងក្រៅឡើយ សេចក្ដីពន្យល់នោះត្រូវចេញពីបរិបទទេពដែលគង់ក្នុងនោះមកវិញ។ ខ្ញុំជឿថាចម្លាក់លើផ្ទាំងជញ្ជាំង ឬលើផ្ដែរនិងហោជាងនៅអង្គរវត្ត ពុំមែនគេឆ្លាក់មកដើម្បីពន្យល់ឬបង្រៀនអ្នកមើលទេ តែគឺជាចម្លាក់សម្រាប់លំអវិមាននៃទេព ហើយចម្លាក់លំអនោះ ធ្វើតម្រូវន័យទៅតាមទិសនិមួយៗ។ ត្រង់នេះហើយដែលខ្ញុំឃើញថា ផ្នែកខ្លះនៃការសង្កេតរបស់បណ្ឌិត Bosch[១៨] សមហេតុផល។ លោកបានពន្យល់ថាហេតុអ្វីបានជាឈុតកូរសមុទ្រទឹកដោះនៅខាងកើត, ហេតុអ្វីបានជាជ័យជំនះនៃព្រះក្រឹស្ណាដែលជាអវតារព្រះនារាយណ៍នៅពេញចំហៀងខាងជើង, ហេតុអ្វីបានជា

[១៣] H. Parmetier, *Modifications subies par le Bayon au cours de son exécution*, BEFEO., XXVII, pp. 149-167.

[១៤] កំណត់អ្នកប្រែ៖ ពាក្យ “យើង” នៅទីនេះ គឺលោក G. Goedès និយាយទៅកាន់បារាំងឬអឺរ៉ុបគ្នាគាត់ មានន័យថាបូជនីយដ្ឋានដែលពោលនោះ គឺបូជនីយដ្ឋាននៅអឺរ៉ុប។

[១៥] កំណត់អ្នកប្រែ៖ កន្លែងនេះអ្នកនិពន្ធប្រើពាក្យសំស្ក្រឹតថា “ប្រទក្សិណបថ”។

[១៦] កំណត់អ្នកប្រែ៖ “ចិត្រសាលា” គឺអាគារឬរោងអ្វីមួយដែលមានគំនូរ។ សូមកុំភ្លេចថា ចម្លាក់នៅតាមផ្ទាំងជញ្ជាំងប្រាសាទ ដូចជាអង្គរវត្តឬបាយ័ន្ត ឬមួយក៏នៅតាមផ្ទាំងថ្ម ពើងឬរូងភ្នំក៏ដោយ ចាស់ៗនៅខេត្តសៀមរាបនិងតំបន់ខាងជើងជាទូទៅហៅថា “គំនូរ” ដូច្នេះឯង។

[១៧] កំណត់អ្នកប្រែ៖ នេះហើយន័យនៃពាក្យថា “ទេវាវិនិច្ឆ័យ”។

[១៨] *Loc. cit.*, pp. 12-17.

ចម្បាំងស្លាប់វង្គាលនៅកុរុក្សេត្រនៅខាងនិរតី, ហើយបរលោកនៅខាងត្បូង។ ប៉ុន្តែខ្ញុំនៅតែគិតថាឈុតទាំងប៉ុន្មានដែលដាច់ពីគ្នា ពុំមែនតគ្នាក្នុងរឿងអ្វីតែមួយនោះ គេមិនឆ្លាក់មកដើម្បីឱ្យដើរមើលតាមឧត្តរពាត់ទេ។ ប្រសិនបើដូច្នេះមែនគេត្រូវចាប់ផ្ដើមមើលពីប្រាសាទជ្រុងនិរតី ដែលជាការពុំសមសោះ។ ខ្ញុំមើលទៅឃើញថាការរាយឈុត តាមទិសនេះគេធ្វើទៅតាមក្បួនច្បាប់ដែលគេស្គាល់ជាទូទៅ។ ទោះបីជាអង្គរវត្តបែទៅខាងកើត ពុំទៅខាងលិច ក៏គង់គេពុំបង្វែរឱ្យផ្ទាំងរឿងស្ថាននរកទៅខាងជើងដែរ។ មើលតែបន្ទាយច្ចារដែលបែមុខទៅខាងកើតនោះទៅ ឃើញហើយថាស្ថាននរកក៏គេបង្ហាញនៅរោងទងខាងត្បូង។ នេះសឱ្យឃើញច្បាស់ថា ជាងឆ្លាក់នោះធ្វើទៅតាមក្បួនច្បាប់ដែលកំណត់មក មិនប្រែប្រួលតាមទិសដើរពាត់ជុំវិញនោះទេ ហើយប្រហែលជាគេមិនដែលគិតថាត្រូវដើរពាត់ជុំវិញនោះផង ក៏សឹងថាបាន។ ដែលនិយាយថាមានរបៀបឬលំដាប់ក្នុងការបង្ហាញចម្លាក់នោះ គឺនិយាយបានតែក្នុងន័យនេះប៉ុណ្ណោះ។

សង្ខេបមក ន័យនៃផ្ទាំងចម្លាក់ធំៗ៣ក្នុងចំណោមផ្ទាំងទាំង៨នៃអង្គរវត្ត មិនគ្រប់គ្រាន់ល្មមឱ្យជឿថា សម្រាប់គេដើរមើលតាមឧត្តរពាត់ទេ។ ទីនេះខ្ញុំសូមបញ្ជាក់បន្តិច៖ ខ្ញុំពុំអះអាងថាគេមិនធ្វើឧត្តរពាត់នោះទេ ហើយជាពិសេសទៅទៀត ខ្ញុំពុំអះអាងថាគេដើរប្រទក្សិណជុំវិញនោះសោះឡើយ។ ខ្ញុំគ្រាន់តែសារភាពថាខ្ញុំពុំយល់ ហើយម្យ៉ាងទៀតខ្ញុំមើលឃើញថា ទ្រឹស្ដីលោក Przyluski ផ្អែកលើមូលដ្ឋានមួយមិនរឹងមាំសោះ ថ្វីត្បិតតែក្នុងនោះអាចមានត្រូវនិងការពិតខ្លះក៏ដោយ។ ប្រសិនបើគាត់អាចបង្ហាញយើងថា នៅប្រទេសកម្ពុជា ឬនៅប្រទេសណាដែលទទួលឥទ្ធិពលឥណ្ឌាដូចគ្នា មានផ្នូរព្រះរាជាដែលគេសាងឱ្យមានរចនាសម្ព័ន្ធរបៀបអង្គរវត្តដែរ ទើបមូលដ្ឋាននោះអាចចាត់ទុកថារឹងមាំខ្លះ។ ឯខ្ញុំវិញមិនដែលប្រទះទេនៅប្រទេសឥណ្ឌាផ្ទាល់។ បើប្រាសាទខ្លះនៅកោះជ្វាដែលគេសម្គាល់បានថាជាផ្នូរក្សត្រនោះ គឺដូចគ្នានិង អង្គរវត្តតែត្រង់បែមុខទៅលិចមួយមុខប៉ុណ្ណោះ។

ឥឡូវនេះឧបមាសិនចុះថាលោក Przyluski យល់ត្រូវហើយដែលថាគេសាងអង្គរវត្ត ដើម្បីទុកតម្កល់ធាតុទាំងអស់ឬធាតុមួយភាគ[១៩] នៃព្រះបាទបរមវិស្ណុលោក។ យើងបានឃើញថា គាត់ចែក "សាកសពមនុស្សលោក"[២០] ដែលពុំអាចដាក់នៅទីណាក្រៅពីផ្នូរ ឱ្យដាច់ណាត់ខុសគ្នាស្រឡះអំពី "ធាតុនៃទេព"[២១] ដែលគួរតែតម្កល់ក្នុងប្រាសាទទើបសមរម្យ។ ការចែកឱ្យខុសគ្នានេះ ដូចជាមិនត្រូវនឹងករណីដែលយើងលើកយកមកពិចារណានេះសោះ។ អ្វីៗដែលយើងដឹងអំពីរាជ្យនិងអំពីកិច្ចបូជាទេវរាជ[២២] បង្ហាញថា គេទុកព្រះរាជាស្មើនឹងទេព តាំងពីព្រះអង្គនៅមានព្រះជន្មម្ល៉េះ។ លុះចូលទីវង្គតទៅសោយសុខនៅស្ថានព្រះនារាយណ៍ហើយក្ខន្ធព្រះអង្គរលាយចូលទៅជាមួយទេពនោះ រីឯនៅធាតុ

---

[១៩] កំណត់អ្នកប្រែ៖ ពាក្យបារាំងនៅទីនេះមិនច្បាស់ទេ ព្រោះអាចសំដៅទៅលើសពដែលមិនដុត ឬមួយក៏ឆ្អឹងដែលសល់ពីដុត សម្រាប់រក្សាទុក ហើយដែលខ្មែរនិយមថា "ធាតុ" ក៏បាន។

[២០] កំណត់អ្នកប្រែ៖ ពាក្យបារាំងគឺ "dépouille d'un mortel"។

[២១] កំណត់អ្នកប្រែ៖ ពាក្យបារាំងគឺ "reliques d'un dieu"។

[២២] G. Coedès. *L'apothéose au Cambodge*, BCAI., 1911, p. 38.

របស់ធាតុព្រះអង្គដែលនៅសល់ គេចាត់ទុកថាជា "ធាតុនៃទេព"។ ប្រការនេះគ្មានអ្វី ឱ្យសង្ស័យឡើយ។ ប្រសិនបើមានផ្នូរមែនសមតែគេសាងផ្នូរនេះឱ្យស្របទៅនឹងស្ថាននៃព្រះនារាយណ៍ ត្បិតព្រះរាជាយាងទៅសោយសុខនៅទីនោះក្រោយពេលចូលទីវង្គតទៅ។ ពោលម្យ៉ាងទៀតគឺថាផ្នូរនោះសមតែជាវិមានឬវាំងនៅស្ថានសួគ៌។

គំនិតនេះហើយដែលយើងឃើញនៅអង្គរវត្ត បើយើងពិនិត្យប្លង់នឹងរូបរាងសំណង់ឱ្យល្អិតល្អន់។ អង្គរវត្តជាភ្នំព្រះសុមេរុដែលមានកំពូលប្រាំ។ ប៉មកណ្ដាលនៅជាន់បាកាណដែលលូតខ្ពស់ជាងគេ ហើយដែលពីមុនមកបើកទ្វារចំហទៅរកទិសទាំងបួននោះ កាលដើមឡើយច្បាស់ជាមានតម្កល់ប្រតិមាមួយអង្គជាប្រាកដ។ បល្ល័ង្កសម្រាប់តម្កល់រូបនោះសោត ក៏នៅនឹងកន្លែងនៅឡើយ។ ដែលយើងមើលទៅឃើញថាអង្គរវត្តលេចធ្លោជាងប្រាសាទឯទៀតជាច្រើនដូចជាបាខែង, ប្រាសាទកែវ, មេបុណ្យ, ប្រែរូប, បាភួនជាដើមនោះ គឺនៅត្រង់ទំហំ និងរោងទង ដែលលាតសន្ធឹងវែងឆ្ងាយតែប៉ុណ្ណោះ។ ប្រាសាទទាំងប៉ុន្មាននោះ សុទ្ធតែនៅផ្នែកកណ្ដាលមានពីរ៉ាមីតមួយតម្កល់ប៉មប្រាំនៅខាងលើ (បួននៅមុម, មួយនៅកណ្ដាល)។ យើងដឹងថាប៉មទាំងនោះសុទ្ធសឹងជាគិភគ្រឹះដែលច្រើនតែតម្កល់រូបស្នងអភិជនដែលគេប្រដូចទៅនឹងទេពក្រោយពេលស្លាប់ទៅ មិនខុសអ្វីពីនៅអង្គរវត្តឡើយ។ នេះជាមូលដ្ឋានគិត ដើម្បីស្រាវជ្រាវរកន័យដើមនៃអង្គរវត្ត ខុសពីគោលគំនិតលោក Przyluski ដែលពុំរឹងមាំទាល់តែសោះ។

មូលដ្ឋានសម្រាប់ពិចារណានេះពុំស្ថិតនៅលើទិសសម្រាប់ដើរដែលទាក់ទងនឹងកិច្ចសពទេ គឺផ្អែកលើប្លង់និងស្ថាបត្យកម្មដែលតម្រូវទៅតាមក្បួនច្បាប់សាងប្រាសាទ។ បើប្រើពាក្យ "ប្រាសាទ"[២៣] ក្នុងន័យថាលំនៅទេព (ទេវាល័យ) ដូចខ្ញុំប្រើដែរ ពោលគឺពុំសំដៅលើកន្លែងសាធារណជនមកគោរពបូជានោះ ការដែលមិនយល់ព្រមហៅអង្គរវត្តថាជា "ប្រាសាទ" ហាក់ដូចជាធ្វើយ៉ាងណាឱ្យតែបានប្រកែក។

ប៉ុន្តែបើលោក Przyluski ថាអង្គរវត្តជា "ផ្នូរ"ក្នុងន័យថាជាទីដែលគេតម្កល់ឬបញ្ចុះធាតុនៃព្រះរាជានោះ ខ្ញុំមិនជំទាស់ទេ ដរាបណាគាត់យល់ដូចខ្ញុំថានៅប៉មកណ្ដាលនៃជាន់បាកាណ គេតម្កល់ប្រតិមាព្រះបាទបរមវិស្ណុលោកក្រោមទិដ្ឋភាពជាព្រះនារាយណ៍។ បើគិតថាគេបញ្ឈរប្រតិមានោះលើបល្ល័ង្ក ដែលក្រោមនោះមានធាតុព្រះរាជាឬធាតុនោះនៅក្រៅបល្ល័ង្កក៏ដោយ ក៏គួរឱ្យជឿដែរ។

ខ្ញុំនឹងសម្រួលជាងនេះទៀតជាមួយលោក Przyluski គឺខ្ញុំមិនជំទាស់ទេនឹងគំនិតថា ដោយសារឆ្អឹងឬធាតុនៅទីនោះហើយបានជាអង្គរវត្តបែទៅខាងលិច។ ខ្ញុំមិនប្រឆាំងនឹងគំនិតថាគេធ្វើឧត្តរពាត់ទៀតផង[២៤] ប្រសិនបើគេធ្វើ

---

[២៣] កំណត់អ្នកប្រែ ៖ ទីនេះពាក្យបារាំងថា "Temple"។

[២៤] កំណត់អ្នកប្រែ ៖ បើថ្ងៃណាមួយគេរកឃើញថាមានរូបសំណាកភ្ជាប់ជាមួយធាតុមនុស្សស្លាប់ ហើយដែលគេធ្វើកិច្ចបូជាដោយដើរឧត្តរពាត់នោះ សេចក្ដី ពន្យល់ដែលខ្ញុំបានធ្វើអំពីបល្ល័ង្កនៅ Tra-kieu (*BEFEO*, XXI, p. 201) ដែល លោក Przyluski ធ្លាប់ប្រឆាំងជំទាស់ (*loc.cit.*, p.332) ដើម្បីការពារគំនិតគាត់ (*RAA*, VI, pp.89-93) នោះ ប្រហែលជាកាន់តែជាក់ច្បាស់មួយកម្រិតទៅទៀត។ ការបកស្រាយរបស់ខ្ញុំថាគេត្រូវមើលចម្លាក់បល្ល័ង្កពីឆ្វេងទៅស្ដាំនោះប្រហែលជាត្រូវ ប្រសិនបើរូបសំណាកដែលបល្ល័ង្កនោះធ្លាប់តម្កល់ទ្រជាប្រតិមាតាងឱ្យមនុស្សដែលស្លាប់ទៅហើយ។ ប៉ុន្តែនិយាយទាំងប៉ុន្មាននេះ នៅក្នុងសម្មតិកម្មទាំងស្រុង ហើយខ្ញុំពុំទាន់ហ៊ានអះអាងអ្វីទាំងអស់។

ដូច្នេះមែន(តែខ្ញុំនៅតែមិនដឹងថាមានឬអត់)។ ប៉ុន្តែយ៉ាងណាក៏ខ្ញុំមិនស្របនឹងគំនិតថាអង្គរវត្តគ្រាន់តែជាផ្នូរ របៀបផ្នូរចិនដែរ។ បើផ្នូរនោះសំដៅថាជាលំនៅព្រះរាជាក្រោយពីចូលទីវង្គតទៅ នោះទើបខ្ញុំយល់ស្រប។ កុំភ្លេចថាមហាក្សត្រខ្មែរពេលអស់ព្រះជន្មទៅ គឺ "យាងទៅស្ថានសួគ៌"[២៥] ដែលមានវាំងជាភិមានអាកាសហើយដែលចំកណ្តាលមានប្រតិមាទេពដែលអាត្មន៍ព្រះរាជាចូលទៅស្ថិតក្នុងនោះ។ ដោយអ្វីៗទាំងអស់ហាក់ដូចជាបង្ហាញថា អ្នកកសាងប្រាសាទជាព្រះរាជាតែម្តង ហើយមួយវិញទៀតដែលក្លាយទៅជាទេពគង់ក្នុងនោះទៀតផង[២៦] (ឬក៏ដែលគេ "កប់បញ្ចុះ" សពព្រះអង្គក្នុងនោះបើតាមលោក Przyluski) បើគិតថាព្រះអង្គសាងវិមានតាំងពីនៅមានព្រះជន្មទុកសម្រាប់គង់នៅក្រោមទិដ្ឋភាពជាប្រតិមាមួយ ក្រោយពីចូលទីវង្គតទៅសម្រាប់គេគោរពបូជានោះ គឺដូចជាសមហេតុសមផលជាងគំនិតថាសាងផ្នូរឆ្ងាយណាស់។

មែនទែនទៅ ខ្ញុំឃើញថាគំនិតខ្វែងគ្នារវាងលោក Przyluski នឹងខ្ញុំស្ថិតនៅលើការប្រើពាក្យ "ប្រាសាទ" និង "ផ្នូរ" ប៉ុណ្ណោះ ហើយខ្ញុំសង្ឃឹមថាគាត់នឹងយល់ព្រមទទួលពាក្យ "ប្រាសាទនៃសព"[២៧] ដែលលោកបណ្ឌិត Bosch[២៨] ប្រើ។

[២៥] *កំណត់អ្នកប្រែ៖ ពាក្យសំស្ក្រឹតថា "ស្វគ៌គត" គឺខ្មែរថា "សួគ៌គត"។ ក្រោយមកខ្មែរប្រឡំតាមសំដីសៀមអាន ក៏សរសេរខុសទៅជា "សុវណ្ណគត" ទៅវិញ។ ប៉ុន្តែខ្មែរនៅស្រុកសុរិន្ទ្រនៅតែអានថា "សួគ៌ត" (ដោយបញ្ចេញសម្លេងរបាទនោះច្បាស់) ដែលជាការធម្មតា ព្រោះជើង "វ" សម័យបុរាណ ច្រើនក្លាយជាស្រះ "អួ" ឬស្រះ "អូ"។*

[២៦] L. Finot, Intro. au vol. 1 du *Temple d'Angkor Vat*, p.7. – Bosch, *Loc cit.*, p. 19.

[២៧] កំណត់អ្នកប្រែ៖ "Temple funéraire"។

[២៨] *Loc. cit.*, pp. 17-21.

## សង្ខេប

### *Aṅkor Vat, temple ou tombeau ?*

អស់រយៈពេលជាច្រើនឆ្នាំ មានការជជែកវែកញែកមួយអំពីអត្ថន័យនៃប្រាសាទបុរាណខ្មែរ ជាពិសេសប្រាសាទអង្គរវត្ត។ មេខ្យល់ធំមានពីរ, ម្ខាងគឺលោក Jean Przyluski ឯម្ខាងទៀតគឺលោក George Coedès។ ម្ខាងយល់ថាអង្គរវត្តជាផ្នូរបញ្ចុះធាតុ ឬសពព្រះបាទសូរ្យវរ្ម័នទី២ ម្ខាងទៀតយល់ថាជាស្ថានព្រះនារាយណ៍ដែលគេសាងឲ្យឃើញជាខ្នាតតូចលើដីយើងនេះ ហើយដែលព្រះបាទសូរ្យវរ្ម័នទី២យាងទៅសោយសុខនៅទីនោះ ក្រោយពីចូលទីវង្គតទៅ។ នៅឆ្នាំ១៩៣៣ លោក Coedès សរសេរអត្ថបទដែលប្រែមកនេះ ដោយបង្ហាញការបន្ធូរបន្ថយជំហរគំនិតខ្លះ តែហាក់ដូចមិនកែប្រែគំនិតជាមូលដ្ឋានរបស់គាត់ឡើយ។ យ៉ាងណាក៏ដោយអត្ថបទនេះបញ្ចប់ការវែកញែកតឹងសរសៃកនោះជាស្ថាពរ។

### Khmer translation of G. Coedès' *"Aṅkor Vat, temple ou tombeau ?"*

A debate over the meaning(s) of ancient Khmer temples, with Angkor Vat as its focal point, raged for a number of years between Jean Przyluski and George Coedès. In short, for Przyluski Angkor Vat was the tomb of the commissioning king, while for Coedès the monument was conceived as the residence of Vishnu, where the said king was to reside after death. Coedès' article, "Angkor Vat : temple or tomb ?," translated here in Khmer, was published in the *Bulletin de l'Ecole Française d'Extrême-Orient* in 1933. The fruit of long reflection incited by the debate in question, the article shows Coedès to have maintained the thrust of his established interpretation while nonetheless presenting a less rigid interpretive approach.

### Traduction en khmer de l'article de G. Coedès *« Aṅkor Vat, temple ou tombeau ? »*

Durant plusieurs années un débat à coup de plume se déroulait sur la (ou les) signification des temples khmers anciens. Angkor Vat en fut le centre. Les protagonistes furent incarnés d'un côté par Jean Przyluski et, de l'autre, par George Coedès. Pour simplifier, Angkor Vat, pour le premier, était la tombe du roi constructeur, et pour le second ce monument était conçu comme la résidence de Vishnu auprès de qui ce roi, après sa mort, est allé résider. L'article de Coedès (« Angkor Vat, temple ou tombeau ? »), ici traduit en khmer, fut publié dans le *Bulletin de l'Ecole Française d'Extrême-Orient* en 1933. Fruit de mûres réflexions suscitées par le débat en question, il montre une position plus adoucie de l'auteur qui, pourtant, ne semble pas avoir cédé sur le fond. Il a en tout cas mis fin au débat.